ការិយាល័យប្រែប្រួលអាកាសធាតុ

ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា

**Climate Change Office**

**Ministry of Environment, Cambodia**



# យន្តការអភិវឌ្ឍន៍ស្អាត នៅកម្ពុជា

# The Clean Development Mechanism in CAMBODIA

បោះពុម្ពលើកទី ២ ២០០៦

2nd Edition 2006







**អាស័យដ្ឋានទាក់ទង :**

***ការិយាល័យប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា***

**ជាន់ទី 2, បន្ទប់លេខ 303B, ក្រសួងបរិស្ថាន**

**#48, មហាវិថីសម្តេចព្រះសីហនុ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**អ៊ីមែល : cceap@online.com.kh ឬ etap@online.com.kh**

**ទូរស័ព្ទ និងទូរសារ :(855-23) 218370**

**គេហទំព័រ : www.camclimate.org.kh**

**កូនសៀវភៅនេះត្រូវបានបោះពុម្ពផ្សាយតាមរយៈគំរោង “*កិច្ចសហប្រតិបត្តិការផ្នែកស្ថាប័ន និងការសន្ទនាពហុជាតិរវាងសហគមន៍អឺរ៉ុប និងអាស៊ី ស្តីពីការជំរុញការចូលរួមពិតប្រាកដរបស់កម្ពុជា ឡាវ និងវៀតណាម នៅក្នុងយន្តការអភិវឌ្ឍន៍ស្អាត*” ដែលផ្តល់មូលនិធិដោយសហគមន៍អឺរ៉ុប ក្រោមកម្មវិធី Asia-Wide ។**

**CONTACT ADDRESS:**

***Cambodian Climate Change Office***

**2nd floor, Room 303B, Ministry of Environment**

**#48, Samdech Preah Sihanouk Blvd, Phnom Penh, Cambodia**

**Email: cceap@online.com.kh or etap@online.com.kh**

**Tel/ Fax:(855-23) 218370**

**Website: www.camclimate.org.kh**

**This brochure is published under the “*EU -Asia Institutional co-operation and Multinational Dialogues on Enabling the Meaningful Participation of Cambodia, Lao PDR and Vietnam in the Clean Development Mechanism (CDM)*” funded By “*European Union under Asia-Wide Programmes*”**

# ការប្រែប្រួលអាកាសធាតុ និងវិធានការឆ្លើយតបជាអន្តរជាតិ

មានភស្តុតាងវិទ្យាសាស្ត្រកាន់តែច្រើនឡើង ដែលថាសកម្មភាពមនុស្សអាចមានផលប៉ះពាល់ដល់អាកាសធាតុពិភពលោក បណ្តាលពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដូចជាឧស្ម័នកាបូនិច មេតាន និងឧស្ម័នមួយចំនួនផ្សេងទៀតពីឧស្សាហកម្ម ។ កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់ នាំឱ្យមានកំណើនកំដៅក្នុងបរិយាកាស ។ សីតុណ្ហភាពមធ្យមនៅលើពិភពលោកបានកើនឡើង 0,7°C រួចមកហើយកាលពីសតវត្សរ៍កន្លងទៅ ។ ការប្រែប្រួលអាកាសធាតុដោយសារសកម្មភាពមនុស្ស ទំនងជានឹងបង្កឱ្យមានឥទ្ធិពលមួយចំនួន ដូចជា កំណើននីវ៉ូទឹកសមុទ្រ ការកើតឡើងញឹកញាប់ជាងមុននូវបាតុភូតអាកាសធាតុមិនប្រក្រតី ដូចជា ខ្យល់ព្យុះស៊ីក្លូន ទឹកជំនន់ និងភាពរាំងស្ងួត ដែលបង្កការខូចខាតចំពោះសេដ្ឋកិច្ច ។



*ស្ថានភាពចរាចរនៅទីក្រុងភ្នំពេញ ឆ្នាំ ២០០១*



*គ្រោះទឹកជំនន់នៅខេត្តកណ្តាល ឆ្នាំ ២០០០*
*Flooding in Kandal Province during 2000*

ដើម្បីដោះស្រាយបញ្ហាបរិស្ថានពិភពលោកបែបនេះ គេបានអនុម័តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅឆ្នាំ 1992 ។ ភាគីជាសមាជិកនៃអនុសញ្ញានេះបានឯកភាព ដើម្បីធ្វើឱ្យមានតុល្យភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសផែនដី ត្រឹមកម្រិតមួយ ដែលអាចរាំងស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់នៃឥទ្ធិពលពីសកម្មភាពមនុស្ស ទៅលើប្រព័ន្ធអាកាសធាតុ ។ នៅខែ ធ្នូ ឆ្នាំ 1997 បណ្តាភាគីជាសមាជិកនៃអនុសញ្ញា UNFCCC បានអនុម័តពិធីសារក្យូតូ ដែលកំណត់ជំហានដំបូងក្នុងការសំរេចទិសដៅនៃអនុសញ្ញា UNFCCC តាមរយៈការប្តេជ្ញាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងបរិមាណកំណត់ ពីសំណាក់បណ្តាប្រទេសឧស្សាហកម្មជឿនលឿន និងកាលវិភាគកំណត់រយៈពេល ដើម្បីសំរេចទិសដៅនេះ ។ ទិដ្ឋភាពសំខាន់បំផុតនៃពិធីសារក្យូតូ ស្ថិតនៅត្រង់ថា បណ្តាប្រទេសឧស្សាហកម្ម (ដែលហៅថាប្រទេសក្នុងឧបសម្ព័ន្ធ B) ត្រូវកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន ក្នុងអត្រាជាមធ្យម 5,2% នៅក្រោមអត្រានៃការបញ្ចេញនាឆ្នាំ 1990 នៅក្នុងដំណាក់កាលទីមួយនៃកាតព្វកិច្ច គឺក្នុងរវាងឆ្នាំ 2008 ទៅ 2012 ។

បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ (ប្រទេសមិននៅក្នុង ឧបសម្ព័ន្ធ B) ពុំមានកាតព្វកិច្ចក្រោមពិធីសារក្យូតូឡើយ ។ ពិធីសារក្យូតូបានចូលជាធរមាននៅឆ្នាំ 2005 ។

## យន្តការអភិវឌ្ឍន៍ស្អាត (Clean Development Mechanism: CDM)

ពិធីសារក្យូតូផ្ដល់ឱកាសឱ្យបណ្ដាប្រទេសឧស្សាហកម្មជឿនលឿនបំពេញកាតព្វកិច្ចរបស់ខ្លួនដោយផ្នែក នៅក្នុងដែនដីនៃប្រទេសដទៃ និងក្រោមកិច្ចសហប្រតិបត្តិការជាមួយប្រទេសទាំងនោះ ។ យន្តការមួយក្នុងចំណោមយន្តការជាច្រើនដែលបានបង្កើតឡើងសំរាប់គោលបំណងនេះ គឺ យន្តការអភិវឌ្ឍន៍ស្អាត (CDM) ដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការរវាងបណ្ដាប្រទេសឧស្សាហកម្មជឿន-លឿន និងប្រទេសកំពុងអភិវឌ្ឍន៍ ។ យន្តការ CDM បំរើគោលបំណងពីរយ៉ាង ។ ទីមួយ យន្តការនេះគឺជាបរិធានសំរាប់ជួយបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការសំរេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព ។ ទីពីរ វាអាចជួយបណ្ដាប្រទេសឧស្សាហកម្មជឿនលឿន ក្នុងការបំពេញកាតព្វកិច្ចនៅក្រោមពិធីសារក្យូតូ ។



*សក្ដានុពលនៃការចាប់យកឧស្ម័នមេតានពីសំណល់រាវដែលបញ្ចេញពីកសិដ្ឋានចិញ្ចឹមជ្រូក*

## គោលគំនិតជាមូលដ្ឋាននៃ CDM

គោលការណ៍របស់ CDM មានលក្ខណៈងាយបំផុត គឺបណ្ដាប្រជាជាតិនៃប្រទេសឧស្សាហកម្មជឿនលឿន (ដែលអាចជារដ្ឋាភិបាល ឬក្រុមហ៊ុនឯកជន) អាចធ្វើការវិនិយោគនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (ប្រទេសជាម្ចាស់ផ្ទះ) លើគំរោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលចំណាយតិច ។ ជាថ្នូរមកវិញ ពួកគេទទួលបានឥណទានសំរាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការអនុវត្តន៍គំរោង (ដែលហៅថា "បរិមាណឧស្ម័នកាត់បន្ថយដែលបានបញ្ជាក់" ឬ CERs) ។ បន្ទាប់មក ប្រទេសដែលជាអ្នកវិនិយោគអាចបូកបញ្ចូលបរិមាណ CERs នេះទៅក្នុងឥណទាននៃការកាត់បន្ថយការបញ្ចេញឧស្ម័ន តាមកាតព្វកិច្ចក្រោមពិធីសារក្យូតូ ។ ដើម្បីអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមពិធីសារក្យូតូ បណ្ដាប្រទេសឧស្សាហកម្មជឿនលឿនត្រូវតែលៃយ៉ាងណា ឱ្យការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រទេសរបស់ខ្លួន ស្ថិតនៅក្នុងកំរិតទាបជាងបរិមាណឥណទានដែលទទួលបាននេះ ។ តាមរយៈការបូកបន្ថែម CERs ពីគំរោង

CDM ទៅក្នុងឥណទានរបស់ខ្លួន បណ្តាប្រទេសឧស្សាហកម្មជឿនលឿនអាចបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រទេសរបស់ខ្លួនក្នុងបរិមាណច្រើនជាងក្នុងករណីដែលពុំបានអនុវត្តន៍គំរោង CDM ។

អត្ថប្រយោជន៍សំខាន់មួយបានពី CDM សំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ស្ថិតនៅត្រង់ថា យន្តការនេះនឹងនាំឱ្យមានការផ្ទេរជាបន្ថែមនូវបច្ចេកវិទ្យាប្រកបដោយនិរន្តរភាព សំរាប់វិស័យមួយចំនួននៅក្នុងបណ្តាប្រទេសជាម្ចាស់ផ្ទះនៃគំរោង CDM ដូចជា ក្នុងវិស័យថាមពល ទេសចរណ៍ ព្រៃឈើ ឧស្សាហកម្ម និងការដឹកជញ្ជូន ។

## គោលការណ៍ជាមូលដ្ឋានសំរាប់ CDM

ដើម្បីធានាថាគំរោង CDM មួយអាចសំរេចគោលដៅទាំងពីរបែបរបស់ខ្លួន ប្រការសំខាន់ពីរដែលចាំបាច់ត្រូវអនុវត្តគឺ :

- អ្នកលើកស្នើគំរោងត្រូវបញ្ជាក់ថា សកម្មភាពដែលស្នើនោះ ពោលគឺការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់) មិនអាចកើតឡើងបានឡើយប្រសិនបើគ្មានគំរោងបែបនេះទេ
- គំរោងនោះត្រូវជំរុញឱ្យមានការអភិវឌ្ឍដោយចីរភាពនៅក្នុងប្រទេសជាម្ចាស់ផ្ទះ ។



*គំរោងផលិតថាមពលដោយពន្លឺព្រះអាទិត្យ នៅខេត្តកំពង់ចាម*
*Solar System Project in Kampong Cham Province*

កត្តាសំខាន់សំរាប់គោលដៅនេះ គំរោង CDM ត្រូវដាក់នៅក្រោមការត្រួតពិនិត្យ នៃក្រុមប្រឹក្សាប្រតិបត្តិ (EB) ដែលធ្វើការនៅក្រោមការចាត់ចែង នៃបណ្តាភាគីជាសមាជិកពិធីសារក្យូតូ ។ ក្រុមប្រឹក្សានេះទទួលខុសត្រូវកំណត់ថា តើគំរោងដែលបានស្នើឡើងណាមួយអាចចាត់ទុកថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចាត់ជាគំរោង CDM ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃគោលដៅទាំងពីរ ដែលមានចែងនៅក្នុងពិធីសារក្យូតូ និងក្នុងគោលការណ៍ណែនាំបន្ថែមកំណត់ដោយ CoP ។

ការសំរេចថា តើគំរោង CDM ដែលបានស្នើឡើង រួមចំណែកក្នុងការអភិវឌ្ឍដោយចីរភាព គឺជាភារៈកិច្ចរបស់រដ្ឋាភិបាលនៃប្រទេសជាម្ចាស់ផ្ទះ ដែលត្រូវផ្តល់ការអនុម័តលើគំរោង CDM នោះ ក្នុងក្របខ័ណ្ឌនៃការរួមចំណែករបស់គំរោងនោះ ចំពោះគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេស និងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់ជាតិ ។

## តើអ្នកណាជាអ្នកលក់ CERs ?

គ្រប់ប្រទេសមិនស្ថិតនៅក្នុងឧបសម្ព័ន្ធ B (រួមទាំងប្រទេសកម្ពុជា) ទោះជារដ្ឋ ឬជាក្រុមហ៊ុនឯកជនក្តី អាចជាអ្នកលក់ CERs ដែលទទួលបានពីគំរោង CDM និងដែលបានអនុវត្តន៏នៅក្នុងដែនដីរបស់ខ្លួន ។ នៅពេលលក់ទៅឱ្យអង្គភាពណាមួយ ដែលមានមូលដ្ឋាននៅក្នុងប្រទេសឧស្សាហកម្មជឿនលឿន បរិមាណ CERs នោះ អាចយកទៅបូកបញ្ចូលដោយផ្ទាល់ទៅក្នុងតណទាននៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៃប្រទេសនោះ ឬអាចលក់បន្តទៅឱ្យភាគីទីបីទៀតដែលត្រូវការ CERs ដើម្បីបំពេញកាតព្វកិច្ចក្រោមពិធីសារក្យូតូ ឬរក្សាទុកក្នុងធនាគារសំរាប់ប្រើប្រាស់នៅពេលក្រោយ ។ អាស្រ័យហេតុនេះអង្គភាពណាមួយដែលមាន CERs ពុំទាន់ប្រើប្រាស់នៅឡើយ ឬដែលបានរក្សាទុកក្នុងធនាគារ ឬដែលបានទិញ និងដែលកំពុងស្វែងរកទីផ្សារដើម្បីលក់ឧស្ម័នផ្ទះកញ្ចក់ តាមបរិមាណដែលបានកាត់បន្ថយ អាចហៅថា អ្នកលក់ CERs ។

នៅដើមឆ្នាំ 2005 ក្នុងចំណោមឧស្ម័នផ្ទះកញ្ចក់ ដែលបានកាត់បន្ថយសរុបតាមរយៈគំរោង CDM "គំរោងត្រៀមបំរុង" មាន 36% ស្ថិតនៅក្នុងបណ្តាប្រទេសនៅអាស៊ី និង 61% នៅអាមេរិចឡាទីន ។ បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលគ្រោងកាត់បន្ថយនៅក្នុងទ្វីបអាហ្វ្រិច មានតិចតួចនៅឡើយទេ ។

## តើអ្នកណាជាអ្នកទិញ CERs?

អ្នកទិញធំជាងគេគឺ ក្រុមហ៊ុនពាណិជ្ជកម្មហិរញ្ញប្បទានកាបូននៃធនាគារពិភពលោក (CFB ដែលតំណាងឱ្យរដ្ឋាភិបាលនៃប្រទេសជាច្រើន និងក្រុមហ៊ុនមួយចំនួននៅអឺរ៉ុប) តាមរយៈមូលនិធិមួយចំនួន ដូចជាមូលនិធិកាបូនប្រូតូតៃប (PCF) មូលនិធិកាបូនអភិវឌ្ឍន៏សហគមន៏ (CDCF) មូលនិធិ BioCarbon និងមូលនិធិរបស់រដ្ឋាភិបាលមួយចំនួន ដូចជាមូលនិធិកាបូនរបស់រដ្ឋាភិបាលអេស្ប៉ាញ និងអ៊ីតាលី ជាដើម ។ រដ្ឋាភិបាលនៃប្រទេសហូឡង់គឺជាអ្នកទិញធំជាងគេបង្អស់ ដែលមានថវិកាប្រមាណ 800 លានអឺរ៉ូ និងប្រើប្រាស់មធ្យោបាយជាច្រើនដើម្បីទិញ ។ រដ្ឋាភិបាលនៃប្រទេសមួយចំនួននៅអឺរ៉ុប ដូចជាប្រទេស អូទ្រីស បែលហ្ស៊ិច ដាណឺម៉ាក់ ហ្វាំងឡង់ និងស៊ុយអែដ បានប្រកាសកម្មវិធីដេញថ្លៃគំរោង CDM ។ នៅក្នុងប្រទេសជប៉ុន មានក្រុមហ៊ុនឯកជនដែលជាអ្នកទិញឧស្ម័នផ្ទះកញ្ចក់កាត់បន្ថយពីគំរោង CDM ក្នុងបរិមាណច្រើនជាងគេបង្អស់ ។ តាមរយៈកម្មវិធីពាណិជ្ជកម្មអឺរ៉ុបលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្រុមហ៊ុននានាអាចប្រើប្រាស់ CERs ដើម្បីបំពេញកាតព្វកិច្ចក្រោមពិធីសារក្យូតូ អាស្រ័យហេតុនេះតំរូវការពីសំណាក់ក្រុមហ៊ុននៅអឺរ៉ុបទំនងជានឹងកើនឡើង ។ បរិមាណតំរូវការសរុបដែលបានគណនាតាមចំនួនអ្នកទិញមានរហូតដល់ 1.000 លានអឺរ៉ូ ។ ឈ្មួញកណ្តាល ដូចជា EcoSecurities, CO2e.Com, Natsource គឺជាអ្នកទាក់ទងរវាងអ្នកទិញ និងអ្នកលក់ ។

## តើ CDM អាចរួមវិភាគទានបែបណាដល់ទិសដៅអភិវឌ្ឍន៍ដោយចីរភាពនៃប្រទេសកំពុងអភិវឌ្ឍន៍ ?

គំរោង CDM ត្រូវតែស្របគ្នាជាមួយអាទិភាពអភិវឌ្ឍដោយចីរភាពនៃប្រទេសជាម្ចាស់ផ្ទះ ។ មានមធ្យោបាយជាច្រើន ដែលអាចជួយធ្វើបែបនេះបាន ដូចជាការបង្កើនលទ្ធភាពប្រើប្រាស់ថាមពលដោយនិរន្តរភាព សំរាប់ផ្គត់ផ្គង់នៅតាមជនបទ ការកាត់បន្ថយភាពក្រីក្រ ការបង្កើតមុខរបរ ការកាត់បន្ថយភាពពឹងផ្អែកលើការទិញថាមពលពីប្រទេសជិតខាង អេកូទេសចរណ៍ ។ល។



ចំការកៅស៊ូនៅខេត្តកំពង់ចាម

លើសពីនេះ ការអនុវត្តកម្មវិធីកសាងសមត្ថភាពសំរាប់ CDM ក្រោមការផ្តល់មូលនិធិពីអ្នកផ្តល់ជំនួយអន្តរជាតិ ក៏ជួយបំពេញគោលដៅអភិវឌ្ឍន៍បែបនេះនៅក្នុងបណ្តាប្រទេសជាម្ចាស់ផ្ទះផងដែរ តាមរយៈការពង្រឹងអង្គភាព/ស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេស និងការបង្កើនការយល់ដឹងអំពី CDM ។

ជាពិសេស ប្រទេសកម្ពុជាអាចទទួលអត្ថប្រយោជន៍ពី CDM តាមរយៈ ÷

- ការកំណត់អាទិភាពវិនិយោគ ដែលបំពេញគោលដៅអភិវឌ្ឍន៍ដោយចីរភាព
- ធ្វើការទាក់ទាញមូលនិធិបន្ថែមសំរាប់គំរោងនានា ដែលអាចរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែបញ្ចេញកាបូនតិច
- លើកទឹកចិត្ត និងអនុញ្ញាតឱ្យមានការចូលរួមយ៉ាងសកម្មពីវិស័យឯកជន និងសាធារណៈ
- ទទួលបាននូវការផ្ទេរបច្ចេកវិទ្យាដោយចីរភាព ដូចជា :
  - ទទួលបាននូវមធ្យោបាយសំរាប់ផលិតថាមពលប្រកបដោយនិរន្តរភាពជាងមុន
  - បង្កើនប្រសិទ្ធភាព និងការសន្សំសំចៃថាមពល
- កាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើនប្រាក់ចំណូល និងមុខរបរ
- កែលំអអត្ថប្រយោជន៍ខាងផ្នែកបរិស្ថាននៅក្នុងមូលដ្ឋាន ។



ប្រព័ន្ធអ៊ីប្រ៊ីត ថាមពលព្រះអាទិត្យ-ជីវៈម៉ាស់នៅក្រុងព្រះសីហនុ

## តើ CDM អាចផ្តល់អ្វីខ្លះដល់ផ្នែកឯកជនក្នុងប្រទេសកម្ពុជា ?

ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន រួមទាំងកម្ពុជាផង ដែលកំពុងស្ថិតនៅក្នុងដំណើរការប្រឹងប្រែងសំរេចគោលដៅកំនើនសេដ្ឋកិច្ច ច្រើនតែទទួលយកនូវបច្ចេកវិទ្យាចាស់ៗមិនទាន់សម័យមកប្រើ ។ ជាទូទៅ បច្ចេកវិទ្យាទាំងនោះប្រើប្រាស់ថាមពលច្រើនជាងបច្ចេកវិទ្យាទំនើបថ្មីៗ ។ យន្តការ CDM អាចនាំឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងមុន (ឬបញ្ចេញ GHG តិចជាង) ។ អាស្រ័យហេតុនេះ តាមរយៈ CDM សហគ្រិនអាច ÷

- ជ្រើសរើសយកបច្ចេកវិទ្យាដែលប្រសើរជាង និងមានប្រសិទ្ធភាពជាង ដែលនាំឱ្យមានការចំណាយតិចជាង
- មានរោងចក្រដែលផ្តល់សុវត្ថិភាពខ្ពស់ជាង និងស្អាតជាងមុន
- រួមវិភាគទានចំពោះការអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេស និងចំពោះកិច្ចការពារបរិស្ថានពិភពលោក ។

ក្រុមហ៊ុន ឬប្រទេសនៅក្នុងឧបសម្ព័ន្ធ B ដែលចូលរួមនៅក្នុងគំរោង CDM អាចផ្តល់ថវិកា ដើម្បីអនុវត្តគំរោងនៅក្នុងប្រទេសដែលមិនស្ថិតនៅក្នុងឧបសម្ព័ន្ធ B ដូចជាប្រទេសកម្ពុជា ដោយប្រើប្រាស់ជំរើសណាមួយ ក្នុងចំណោមជំរើសដូចខាងក្រោមនេះ

### ⇨ កិច្ចព្រមព្រៀងជាវ CER ÷

ក្រុមហ៊ុនមួយឯកភាពទិញ CERs ដែលបង្កើតបាន តាមរយៈគំរោង CDM ។

គំរោង CDM ស្ទើរតែទាំងអស់អនុវត្តតាមគំរូបែបនេះ ដែលមានន័យថា ក្រុមហ៊ុនក្នុងប្រទេសកម្ពុជាត្រូវតែរៀបចំគំរោង CDM ហើយរកមូលនិធិដោយខ្លួនឯង ។ នៅពេលអនុវត្តគំរោងនោះ ទើបអ្នកវិនិយោគអាចទទួលបានប្រាក់ចំណូលពីការលក់ CERs ។ ក្នុងករណីតិចតួចបំផុតអាចមានការចរចាអំពីកិច្ចព្រមព្រៀងជាវ CERs ដោយអាចផ្តល់ហិរញ្ញវត្ថុជាមុនខ្លះៗ ។

### ⇨ ភាគហ៊ុនផ្ទាល់ខ្លួនសរុប ឬមួយចំណែក ÷

ក្រុមហ៊ុនមួយផ្តល់មូលនិធិទាំងស្រុង ឬដាក់ហ៊ុនជាមួយគ្នា ដើម្បីអនុវត្តន៍គំរោង CDM សំដៅទទួលប្រាក់ចំណូលមកវិញទាំងស្រុង ឬមួយចំណែក និង CERs ។ ករណីបែបនេះកំរកើតមានណាស់ ។

### ⇨ ប្រាក់កម្ចី ÷

ក្រុមហ៊ុនមួយ ឬធនាគារផ្តល់ប្រាក់កម្ចីឬបណ្តាក់ទុន ដោយអត្រាការប្រាក់មួយកំណត់ជាការប្តូរនឹង CERs ។ ករណីបែបនេះពុំសូវមានទេ ដោយសារមកទល់ពេលនេះ ស្ថាប័នហិរញ្ញវត្ថុមានការយល់ដឹងតិចតួចអំពី CDM ។

ប៉ុន្តែក្នុងករណីភាគច្រើនគំរោង CDM អាចជួយផ្តល់មូលនិធិដែលត្រូវការសំរាប់បំពេញបន្ថែមលើថ្លៃចំណាយធៀបនឹងគំរោងធម្មតា ឬអាចផ្តល់ហិរញ្ញវត្ថុ ដើម្បីលុបបំបាត់នូវឧបសគ្គខាងទីផ្សារ ដើម្បីឱ្យគំរោងនោះអាចមានលទ្ធភាពទទួលបានហិរញ្ញវត្ថុ ។

## វិធានការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹង CDM

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ CDM ថាជាឱកាសដើម្បីឈានទៅសំរេចទិសដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រ ។ រាជរដ្ឋាភិបាលបានអនុវត្តសកម្មភាពសំខាន់ៗ ដើម្បីបំពេញលក្ខណៈវិនិច្ឆ័យ សំរាប់ការវិនិយោគសមស្របនៅក្នុងប្រទេស ដោយបានផ្តល់សច្ចាប័នលើពិធីសារក្យូតូនៅឆ្នាំ 2002 និងបានបង្កើតស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (DNA) ។

## សកម្មភាព CDM នៅប្រទេសកម្ពុជា

មានសកម្មភាពកសាងសមត្ថភាពមួយចំនួន បានប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃការរៀបចំ ដើម្បីឱ្យមានការវិនិយោគគំរោង CDM នៅក្នុងប្រទេសកម្ពុជា ។ សកម្មភាពដំបូងគេ គឺគំរោងកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត (CD4CDM) ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលនៃប្រទេសហូឡង់ តាមរយៈ មជ្ឈមណ្ឌលសហប្រតិបត្តិការខាងផ្នែកថាមពលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព របស់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ។




*សិក្ខាសាលាថ្នាក់តំបន់ ស្តីពីការកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត នៅខេត្តសៀមរាប ថ្ងៃទី ២៤-២៦ ខែមីនា ឆ្នាំ ២០០៤*

សកម្មភាពទីពីរគឺ គំរោងពង្រឹងសមត្ថភាពចំរុះសំរាប់យន្តការអភិវឌ្ឍន៍ស្អាត (ICS-CDM) ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលជប៉ុន តាមរយៈវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (IGES) ។ កិច្ចផ្តួចផ្តើមទីបី ដែលផ្តោតជាសំខាន់លើការកសាងសមត្ថភាពសំរាប់ CDM គឺ គំរោង "ការសន្ទនាអាស៊ី-អឺរ៉ុបស្តីពី CDM " នៅក្រោមកម្មវិធី Asia Pro-Eco ។




*ការតាំងពិពណ៌ទីផ្សារគំរោងកាត់បន្ថយការបញ្ចេញការបូន នៅឆ្នាំ 2005 នៅប្រទេសអាល្លឺមង់*

កម្ពុជាគឺជាប្រទេសមួយ ក្នុងចំណោមប្រទេសចំនួនបីដែលចូលរួមអនុវត្តគំរោងនេះ ។ គំរោងទាំងនេះមានទិសដៅ បង្កើនការយល់ដឹងអំពី CDM ផ្តល់ព័ត៌មានអំពីប្រវត្តិទាក់ទងនឹងលក្ខខណ្ឌ និងអត្ថប្រយោជន៍សំរាប់អ្នករៀបចំគោលនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ លើសពីនេះ គំរោងទាំងនេះផ្តល់ការគាំទ្រ ក្នុងការបង្កើតស្ថាប័នជាតិទទួលបន្ទុក CDM ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រី និងអ្នកពាក់ព័ន្ធជាមួយ CDM នៅក្នុងប្រទេស រៀបចំដំណើរការវាយតំលៃសំរាប់គំរោង CDM ក្រោមកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ជាមួយក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ។ ទីបំផុត កិច្ចផ្តួចផ្តើមទាំងនេះមានគោលដៅរៀបចំសំណើគំរោង CDM ដែលមានសក្តានុពល និងផ្សព្វផ្សាយគំរោងទាំងនោះក្នុងចំណោមអ្នករៀបចំគំរោង និងវិនិយោគិន ។

## វិស័យដែលមានសក្តានុពលសំរាប់គំរោង CDM ក្នុងប្រទេសកម្ពុជា

ជាទូទៅ វិស័យនានាដែលមានសក្តានុពលធំធេងសំរាប់គំរោង CDM ក្នុងប្រទេសកម្ពុជារួមមាន :

- ថាមពលកកើតឡើងវិញ
- ប្រសិទ្ធភាពថាមពល
- ការចាប់យកឧស្ម័នមេតានពីទីលានចាក់សំរាម
- ការដាំព្រៃឈើ និងការស្តារព្រៃឈើឡើងវិញ ។



*ទឹកធ្លាក់នៅខេត្តកំពត*

ដោយឡែក គំរោង CDM ខ្នាតតូច (SSC) គឺជាគំរោងដែលមានសក្តានុពលខ្ពស់ជាងគេ ព្រោះថា គំរោងទាំងនោះមានលក្ខណៈសមស្រប សំរាប់ប្រទេសកម្ពុជា ទោះបីគំរោងបែបនោះមានសមត្ថភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងកំរិតទាបក៏ដោយ ។ សកម្មភាពគំរោង CDM ខ្នាតតូច គឺរាល់គំរោងដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ដែលកំនត់ដោយ EB ។ នៅពេលគំរោង

ដែលបានស្នើឡើង ត្រូវបានចាត់ទុកថាជាគំរោង CDM ខ្នាតតូច វាមានលក្ខណៈងាយស្រួល ដោយសារគំរោងនោះតំរូវឱ្យមានការប្រើប្រាស់តែបែបបទ និងនីតិវិធីងាយៗតែប៉ុណ្ណោះ សំរាប់អនុវត្ត ។ ក្រុមប្រឹក្សាប្រតិបត្តិគំរោងនឹងរៀបចំព្រមទាំងកែសំរួលជាបន្ថែមអំពីសេចក្តីលំអិត និងបទបញ្ជាសំរាប់គំរោង CDM ខ្នាតតូច ។



កសិដ្ឋានចិញ្ចឹមជ្រូកនៅខេត្តកណ្តាល



ទីលានចាក់សំរាម ស្ទឹងមានជ័យ ក្រុងភ្នំពេញ

គំរោង CDM ខ្នាតតូចប្រភេទខ្លះដែលអាចជាការចាប់អារម្មណ៍ សំរាប់ប្រទេសកម្ពុជា គឺ :

- **ថាមពលកកើតឡើងវិញ** ( ប្រព័ន្ធអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យដំឡើងតាមគេហដ្ឋាន គំរោងវារីអគ្គិសនីខ្នាតតូច គំរោងផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ/កំលាំងខ្យល់ សំរាប់បញ្ចូលអាគុយ គំរោងផលិតថាមពលពីជីវៈម៉ាស) ។
- **ការកែលំអប្រសិទ្ធភាពថាមពល**

  ( ទាំងខាងផ្នែកផ្គត់ផ្គង់ ដូចជាការកែលំអប្រសិទ្ធភាពម៉ាស៊ីនផលិតថាមពលដែលដើរដោយឥន្ធនៈផូស៊ីល និងខាងផ្នែកប្រើប្រាស់ ដូចជាការប្តូរបរិក្ខារដែលកំពុងប្រើប្រាស់ ឬតំឡើងបរិក្ខារថ្មីដែលស៊ីភ្លើងតិច នៅតាមសណ្ឋាគារ មណ្ឌលទេសចរណ៍ ។ល ។)
- **ការចាប់យកមេតាន និងការជៀសវាងការបញ្ចេញឧស្ម័នមេតានពីសកម្មភាពកសិឧស្សាហកម្ម ទីលានចោលសំរាម កន្លែងធ្វើប្រព្រឹត្តកម្មសំអាតទឹកសំអុយ និងពីប្រភពផ្សេងៗទៀត ។**

## ខ្លឹមសារអំពីគំរោង CDM

- ***ឈ្មោះគំរោង :*** *គំរោងផលិតថាមពលពីការដុតអង្កាម Angkor Bio Cogen (ABC)*
- ***ការពិពណ៌នាអំពីគំរោង :***

គំរោងនេះត្រូវបានបង្កើតឡើង ដោយប្រើប្រាស់អង្កាមសំរាប់ផលិតអគ្គិសនី ដែលប្រសិនបើពុំមានគំរោងនេះ អង្កាមនឹងត្រូវទុកឱ្យរលួយចោល ។ គំរោងនេះតំរូវឱ្យមានការសាងសង់ និងដាក់ឱ្យដំណើរការនូវម៉ាស៊ីនផលិតអគ្គិសនីដើរដោយអង្កាម ដែលមានសមត្ថភាពសរុប 1,5MWe នៅក្បែរ**រោងម៉ាស៊ីនកិនស្រូវអង្គររុងរឿង** ក្នុងខេត្តកណ្ដាលនៃប្រទេសកម្ពុជា ។ បច្ចុប្បន្ន រោងចក្រនេះនៅប្រើប្រាស់ប្រេងម៉ាស៊ូត ដើម្បីផលិតអគ្គិសនីសំរាប់ផ្គត់ផ្គង់ដំណើរការម៉ាស៊ីនកិនស្រូវ ។ គំរោងនេះនឹងប្ដូរម៉ាស៊ីនដើរដោយប្រេងម៉ាស៊ូតចេញ ។ ថាមពលអគ្គិសនីបានពីគំរោង និងដែលប្រើប្រាស់មិនអស់សំរាប់ម៉ាស៊ីនកិនស្រូវ អាចនឹងលក់ទៅឱ្យរោងចក្រនៅជិតខាង និងទៅសហគមន៍ដែលរស់នៅក្បែរនោះ ។ គំរោងនេះ ក៏នឹងជួយបញ្ចៀសការបញ្ចេញឧស្ម័នមេតាន ដែលកើតឡើងពីការរលួយនៃអង្កាមផងដែរ ។ គំរោងនេះអាចជួយកាត់បន្ថយការបញ្ចេញឧស្ម័ន 45.815t $CO_2$eq ក្នុងមួយឆ្នាំ ។

- ***តើគំរោងនេះរួមវិភាគទានបែបណាចំពោះគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេស ?***

គំរោងនេះនឹងជួយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយប្រើប្រាស់ប្រភពថាមពលកើតឡើងវិញ ដែលអាចត្រូវទុកចោល ប្រសិនបើគ្មានគំរោងនេះទេ ។ លើសពីនេះ តាមរយៈការកាត់បន្ថយការបំពុលខ្យល់នៅក្នុងមូលដ្ឋាន និងរក្សាស្ថេរភាពនៃការប្រើប្រាស់ដីធ្លី គំរោងនេះនឹងរួមចំណែកដល់កិច្ចការពារបរិស្ថានក្នុងមូលដ្ឋាន ព្រមទាំងលើកកំពស់ការវិនិយោគនៅក្នុងតំបន់នោះ និងនៅក្នុងប្រទេសកម្ពុជាទាំងមូល ។ ក្រៅពីនេះ គំរោងនេះអាចនាំមកនូវអត្ថប្រយោជន៍សង្គមសំរាប់សហគមន៍ដែលរស់នៅជិតខាង ដោយគំរោងនេះអាចផ្ដល់អគ្គិសនីមួយចំណែកតូចដល់សហគមន៍ទាំងនោះក្នុងតំលៃសមស្រប ប្រសិនបើប្រៀបធៀបនឹងថ្លៃអគ្គិសនី ដែលអ្នកប្រើប្រាស់ត្រូវបង់ នាពេលបច្ចុប្បន្ន ។ អាស្រ័យហេតុនេះ គំរោងនេះនឹងរួមវិភាគទាន ដល់គោលដៅកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ។

## តើអ្នករៀបចំគំរោងអាចស្វែងរកការគាំទ្រសំរាប់គំរោង CDM ពីទីណា ?

ការិយាល័យប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា (CCCO) បានបង្កើតឡើង នៅខែកក្កដា ឆ្នាំ 2003 នៅក្នុងក្រសួងបរិស្ថាន ។ ចាប់ពីឆ្នាំ 2003 ការិយាល័យប្រែប្រួលអាកាសធាតុបានដើរតួជាលេខាធិការដ្ឋានសំរាប់ CDM ។

ស្ថាប័នជាតិ CDM មានភារៈទទួលខុសត្រូវធ្វើការវាយតំលៃគំរោង CDM ដែលបានស្នើឡើង ធៀបនឹងលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍដោយចីរភាពរបស់ជាតិ និងមានសមត្ថកិច្ចចេញលិខិតបញ្ជាក់ថា សំណើគំរោងមួយសមស្របតាមលក្ខណៈវិនិច្ឆ័យទាំងនោះ ។ ប្រទេសកម្ពុជាប្រើប្រាស់តារាងម៉ាទ្រិច អំពីលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍដោយចីរភាព

សំរាប់ជាឧបករណ៍វាយតំលៃលើការរួមចំណែករបស់គំរោងចំពោះការអភិវឌ្ឍដោយចីរភាព ដោយផ្អែកលើទិដ្ឋភាពបួនយ៉ាងនៃការអភិវឌ្ឍ ពោលគឺ ទិដ្ឋភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងការផ្ទេរបច្ចេកវិទ្យា ។

ការិយាល័យប្រែប្រួលអាកាសធាតុអាចជួយដល់អ្នក រៀបចំគំរោង CDM ដូចខាងក្រោមនេះ :

- ផ្តល់ប្រឹក្សាអំពីការរៀបចំគំរោង CDM
- សំរបសំរួលឱ្យមានការពិគ្រោះយោបល់ទូលំទូលាយជាមួយបណ្តាអ្នកពាក់ព័ន្ធនៅក្នុងប្រទេស
- ណែនាំដល់អ្នករៀបចំគំរោងឱ្យស្គាល់អង្គភាពដែល អាចជាអ្នកទិញ CERs ។

## ដំណើរដាក់ជូនគំរោង CDM ទៅស្ថាប័ន DNA និងឯកសារចាំបាច់

ជាដំបូង អ្នករៀបចំគំរោង CDM ត្រូវដាក់ជូនឯកសាររបស់ខ្លួន ដោយរួមទាំងឯកសាររៀបចំគំរោង (PDD) ទៅលេខាធិការដ្ឋាន DNA នៃប្រទេសកម្ពុជា ដែលមានមូលដ្ឋាននៅក្នុងការិយាល័យប្រែប្រួលអាកាសធាតុ ដើម្បីពិនិត្យពីភាពពេញលេញរបស់ PDD ។ បន្ទាប់មក លេខាធិការដ្ឋានដាក់បញ្ជូន PDD ទៅក្រុមការងារបច្ចេកទេសដែលពាក់ព័ន្ធ ដើម្បីធ្វើការវាយតំលៃផ្អែកលើលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍប្រកបដោយចីរភាព និងលក្ខណៈវិនិច្ឆ័យដទៃទៀតរបស់ប្រទេស ។

ឯកសារនានាដូចខាងក្រោមនេះ អាចតំរូវឱ្យដាក់ភ្ជាប់ជាមួយឯកសាររៀបចំគំរោង (PDD) :

1) លិខិតអនុញ្ញាតធ្វើការវិនិយោគតាមការចាំបាច់ (ដោយទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាជ្ញាធរខេត្ត-ក្រុង ។ល។)
2) របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ប្រសិនតំរូវឱ្យធ្វើ ។

រាល់ឯកសារដាក់ជូនត្រូវតែសរសេរជាភាសាអង់គ្លេស ។

នីតិវិធីក្នុងការអនុម័តគំរោង CDM នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចែកជាបីដំណាក់កាល ហើយត្រូវការពេលវេលាសរុបប្រមាណ 55 ថ្ងៃធ្វើការ ។

- **ជំហានទី I** ត្រូវការរយៈពេលប្រមាណ 10 ថ្ងៃធ្វើការ សំរាប់ឱ្យលេខាធិការដ្ឋាន DNA ពិនិត្យឯកសារ PDD ជាលើកដំបូង ថាតើមានភាពពេញលេញគ្រប់គ្រាន់ហើយឬនៅ
- **ជំហានទី II** ត្រូវការរយៈពេលប្រមាណ 30 ថ្ងៃធ្វើការ សំរាប់ធ្វើការវាយតំលៃលក្ខណៈបច្ចេកទេសលើឯកសារ PDD ដោយប្រើប្រាស់តារាងម៉ាទ្រិចនៃការអភិវឌ្ឍដោយចីរភាព និងការប្រមូលយោបល់ពីអ្នកពាក់ព័ន្ធនានា ដែលបានផ្តល់ជូនលេខាធិការដ្ឋាន DNA ទាក់ទងនឹងសំណើគំរោងនោះ
- **ជំហានទី III** ត្រូវការរយៈពេលប្រមាណ 15 ថ្ងៃធ្វើការ សំរាប់ឱ្យក្រុមប្រឹក្សា DNA ធ្វើសេចក្តីសំរេចលើសំណើគំរោង មុនចេញលិខិតអនុម័តឯកភាព ឬបដិសេធ ។

## គំនូសតាងអំពីដំណើរការអនុម័តគំរោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ក្នុងប្រទេសកម្ពុជា
## (រយៈពេលធ្វើការអនុម័ត ៥៥ ថ្ងៃធ្វើការ)



## បែបបទនៃការវិនិយោគសំរាប់សំណើគំរោង CDM ក្នុងប្រទេសកម្ពុជា

រាល់គំរោង CDM ត្រូវគោរពតាមច្បាប់ស្តីពីការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនៅឆ្នាំ 1994 និងវិសោធនកម្មនៅឆ្នាំ 2003 ដែលចែងពីស្ថាប័ន និងមូលដ្ឋានច្បាប់សំរាប់ធ្វើការវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា (CDC) គឺជាស្ថាប័នរបស់រដ្ឋាភិបាល ដែលទទួលខុសត្រូវលើការរៀបចំ និងគ្រប់គ្រងការវិនិយោគបរទេសផ្ទាល់ (FDI) ។ CDC គឺជាអង្គភាពប្រតិបត្តិទទួលបន្ទុករៀបចំយុទ្ធសាស្ត្រវិនិយោគ និងផ្តល់ការឯកភាព ឬបដិសេធសំណើធ្វើការវិនិយោគ ។ ដំណើរការអនុម័តលើការវិនិយោគទាមទាររយៈពេលយូរបំផុត 28 ថ្ងៃ ។

អាស្រ័យតាមប្រភេទ និងទំហំនៃសកម្មភាពគំរោង ច្បាប់ក្នុងប្រទេសកម្ពុជាអាចតំរូវឱ្យរាល់គំរោង CDM ដែលអនុវត្តក្នុងប្រទេសកម្ពុជា ធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ។ មិនមែនគ្រប់សំណើគំរោង CDM សុទ្ធតែត្រូវភ្ជាប់ជាមួយនូវរបាយការណ៍ EIA នោះឡើយ ប៉ុន្តែជាទូទៅគំរោងដែលស្ថិតនៅក្នុងក្រុមណាមួយដូចខាងក្រោមនេះសុទ្ធតែត្រូវការឱ្យមានរបាយការណ៍ EIA : រោងចក្រថាមពលដែលមានសមត្ថភាពផលិតធំជាង ឬស្មើ 5MW រោងចក្រថាមពលវារីអគ្គិសនី ដែលមានសមត្ថភាពផលិតធំជាង ឬស្មើ 1MW សកម្មភាពកសិកម្ម និងកសិឧស្សាហកម្មលើផ្ទៃដីធំជាង ឬស្មើ 10.000 ហិចតា ។

គំរោង CDM ស្តីពីការដាំព្រៃឈើ ឬស្តារព្រៃឈើឡើងវិញ ត្រូវគោរពតាមច្បាប់ព្រៃឈើ ដែលមានគោលដៅធានាគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។ គំរោងថាមពល CDM ដែលផលិតអគ្គិសនី ត្រូវគោរពតាមច្បាប់អគ្គិសនីដែលចែងពីការគ្រប់គ្រងការងារឧស្សាហកម្មថាមពល ។

# សេចក្តីសង្ខេបអំពីច្បាប់សំខាន់ៗ ពាក់ព័ន្ធនឹងគំរោង CDM ក្នុងប្រទេសកម្ពុជា



# តារាងវាយតម្លៃគំរោង និងការអភិវឌ្ឍដោយចីរភាព

| លក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន | ការវាយតម្លៃ |
|---|---|
| **ប្រភេទទី 1. កិច្ចការពារ និងកែលំអបរិស្ថាន** | |
| 1.1 ការរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅលើពិភពលោក | + កាត់បន្ថយ ឬបញ្ចៀសការបញ្ចេញឧស្ម័នផ្ទះកញ្ចក់<br>↑<br>0 មិនមានការប្រែប្រួលក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់<br>↓<br>- បង្កើនការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ |
| 1.2 ការកាត់បន្ថយការបំពុលខ្យល់ ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង | + កាត់បន្ថយកំរិតនៃសាធាតុបំពុលខ្យល់ ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↑<br>0 មិនធ្វើឱ្យប្រែប្រួលកំរិតនៃសារធាតុបំពុលខ្យល់ ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↓<br>- បង្កើនកំរិតបំពុលខ្យល់ ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង |
| 1.3 ការកាត់បន្ថយការបំពុលទឹក ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង | + កាត់បន្ថយកំរិតបំពុលទឹក ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↑<br>0 មិនធ្វើឱ្យប្រែប្រួលកំរិតបំពុលទឹក ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↓<br>- បង្កើនកំរិតបំពុលទឹក ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង |
| 1.4 កាត់បន្ថយការបំពុលដីដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង | + កាត់បន្ថយកំរិតបំពុលដី ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↑<br>0 មិនធ្វើឱ្យប្រែប្រួលកំរិតបំពុលដី ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↓ |

| លក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន | ការវាយតំលៃ |
|---|---|
| | - បង្កើនកំរិតបំពុលដី ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបាន កំណត់នៅក្នុងឯកសារប្លង់គំរោង |
| 1.5 កាត់បន្ថយការរំខានដោយសំលេងដោយ ប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង | ✚ កាត់បន្ថយកំរិតរំខានដោយសំលេង ដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↑<br>0 មិនធ្វើឱ្យប្រែប្រួលកំរិតរំខានដោយសំលេងដោយប្រៀបធៀបជាមួយ សេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង<br>↓<br>- បង្កើនកំរិតរំខានដោយសំលេងដោយប្រៀបធៀបជាមួយសេណារីយោគោល ដូចបានកំណត់នៅក្នុងឯកសារប្លង់គំរោង |
| 1.6 ការអភិរក្សជីវៈចំរុះ | ✚ បង្កើនជីវៈចំរុះក្នុងស្រុក នៅកំរិតប្រព័ន្ធអេកូឡូស៊ី កំរិតប្រភេទ និង/ឬ កំរិតសែន ។ ឧទាហរណ៍ :<br>• ការពង្រីកទីជំរកសំរាប់ប្រភេទជិតផុតពូជ<br>• សកម្មភាពដែលបង្កើនប្រភេទក្នុងស្រុកច្រើនយ៉ាង<br>↑<br>0 គ្មានផលប៉ះពាល់លើជីវៈចំរុះក្នុងស្រុក នៅកំរិតប្រព័ន្ធអេកូឡូស៊ី កំរិតប្រភេទ និង/ឬ កំរិតសែន ។ ឧទាហរណ៍ :<br>• សកម្មភាពរបស់ប្រភេទមួយត្រូវបានដោះស្រាយគ្រប់គ្រាន់តាមរយៈការបង្កើតឱ្យមានរបៀង និងតំបន់ទ្រនាប់<br>• រៀបចំជាស្រេចនូវផែនការគ្រប់គ្រង/អនុវត្តន៍ ដើម្បីការពារប្រភេទ និងទីជំរកនៃប្រភេទទាំងនោះ<br>↓<br>- កាត់បន្ថយជីវៈចំរុះក្នុងស្រុកនៅកំរិតប្រព័ន្ធអេកូឡូស៊ី ប្រភេទ និង/ឬកំរិតសែន ។ ឧទាហរណ៍ :<br>• ការរានព្រៃ ឬការលិចលង់ទីជំរកអេកូឡូស៊ី<br>• ការធ្វើឱ្យបាត់បង់ និង/ឬបង្កឱ្យមានផលប៉ះពាល់លើប្រភេទជិត ផុតពូជ និង/ឬ ទីជំរកនៃប្រភេទទាំងនោះ<br>• ការធ្វើឱ្យបាត់បង់ភាពសំបូរបែបនៃប្រភេទ និងជំនួសដោយប្រភេទ តែមួយ ឬពីរ |

| លក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន | ការវាយតំលៃ |
|---|---|
| 1.7 ការប្រើប្រាស់ធនធានដីដោយនិរន្តរភាព | ✚ កែលំអធនធានដី<br>🡅<br>0 គ្មានផលប៉ះពាល់អាក្រក់ដល់ធនធានដី<br>🡇<br>- ការប្រើប្រាស់ដីដោយគ្មាននិរន្តរភាព ឬការរេចរីលដី |
| 1.8 ការប្រើប្រាស់ធនធានរ៉ែដោយនិរន្តរភាព | 0 ការប្រើប្រាស់ធនធានរ៉ែដោយសមហេតុសមផល<br>🡇<br>- ការប្រើប្រាស់ធនធានរ៉ែដោយគ្មានប្រសិទ្ធភាព |
| 1.9 ការប្រើប្រាស់ធនធានព្រៃឈើដោយ និរន្តរភាព | ✚ ការកែលំអធនធានព្រៃឈើ<br>🡅<br>0<br>• គ្មានផលប៉ះពាល់លើធនធានព្រៃឈើ<br>• មានផែនការគ្រប់គ្រង និងអនុវត្តដើម្បីកាត់បន្ថយផលបប៉ះពាល់<br>🡇<br>- ការប្រើប្រាស់ដោយគ្មាននិរន្តរភាព ឬការបាត់បងធនធានព្រៃឈើ |
| 1.10 ការប្រើប្រាស់ធនធានទឹកដោយនិរន្តរភាព | ✚ ការកែលំអធនធានទឹក<br>🡅<br>0<br>• គ្មានផលប៉ះពាល់លើធនធានទឹក<br>• មានផែនការគ្រប់គ្រង និងអនុវត្តដើម្បីកាត់បន្ថយផលបប៉ះពាល់<br>🡇<br>- ការប្រើប្រាស់ដោយគ្មាននិរន្តរភាព ឬការបាត់បង់ធនធានទឹក |
| 1.11 បេតិកភណ្ឌបុរាណវត្ថុ វប្បធម៌ ប្រវត្តិសាស្ត្រ និងជំនឿ | ✚ ពង្រឹងការថែរក្សាទីតាំងបុរាណវត្ថុ វប្បធម៌ ប្រវត្តិសាស្ត្រ ឬទីគោរពបូជា<br>🡅<br>0 គ្មានផលប៉ះពាល់ចំពោះទីតាំងបុរាណវត្ថុ វប្បធម៌ ប្រវត្តិសាស្ត្រ ឬ ទីគោរពបូជា<br>🡇<br>• ផលប៉ះពាល់អវិជ្ជមានលើទីតាំងបុរាណវត្ថុ វប្បធម៌ ប្រវត្តិសាស្ត ឬទីគោរពបូជា<br>• ផលប៉ះពាល់អវិជ្ជមានចំពោះសិទ្ធិក្នុងការចេញចូលទីតាំងបុរាណវត្ថុ វប្បធម៌ ប្រវត្តិសាស្ត្រ ឬទីគោរពបូជា<br>- |

| លក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន | ការវាយតម្លៃ |
|---|---|
| **ប្រភេទទី 2. ទិដ្ឋភាពសង្គម : ការបង្កើនប្រាក់ ចំណូល និងលើកស្ទួយជីវភាព** | |
| 2.1 ការកាត់បន្ថយភាពក្រីក្រ | ✚<br>• បង្កើនឱកាសរកចំណូលសំរាប់ប្រជាជនមូលដ្ឋាន<br>• លើកស្ទួយជីវភាពរបស់ប្រជាជនមូលដ្ឋាន ជាពិសេសក្រុមជនក្រីក្រ និងទន់ខ្សោយ<br>🡅<br>0 គ្មានផលប៉ះពាល់លើជីភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន<br>🡇<br>• ធ្វើឱ្យប្រជាជនបាត់បង់លទ្ធភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិសំរាប់រកចំណូល<br>• ជំលៀសប្រជាជនដោយពុំផ្តល់ជំរើសផ្សេងសំរាប់ជាមធ្យោបាយរកចំណូល<br>- |
| 2.2 ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៏ | ✚ ការកសាងហេដ្ឋារចនាសម្ព័ន្ធសហគមន៏ ( អណ្តូង ផ្លូវថ្នល់ សាលារៀន) ។<br>🡅<br>0 គ្មានផលប៉ះពាល់ចំពោះហេដ្ឋារចនាសម្ព័ន្ធសហគមន៏<br>🡇<br>- ការធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធសំរាប់សហគមន៏ ( អណ្តូង ផ្លូវថ្នល់ សាលារៀន ។ល ។) បណ្តាលមកពីសកម្មភាពពាក់ព័ន្ធនឹងគំរោង |
| 2.3 ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ | ✚<br>• ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធមានធ្វើចាប់តាំងពីពេលចាប់ផ្តើមគំរោង<br>• ការរៀបចំប្លង់គំរោងបានធ្វើឡើងរួមគ្នាជាមួយភាគីពាក់ព័ន្ធ<br>• ភាគីពាក់ព័ន្ធក្នុងមូលដ្ឋានគាំទ្រគំរោង<br>• ការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការធ្វើសេចក្តីសំរេច<br>🡅<br>0 មានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងបានរកឃើញថា ផលប៉ះពាល់មានកំរិតអប្បបរមា<br>🡇<br>• គ្មានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ<br>• ការបដិសេធយោបល់របស់ភាគីពាក់ព័ន្ធ |

| លក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន | ការវាយតំលៃ |
|---|---|
| | • ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធមានធ្វើឡើងតែនៅដំណាក់កាលចុងបញ្ចប់នៃការរៀបចំប្លង់គំរោង ដោយមិនផ្តល់ឱកាសដើម្បីធេវិការកែតំរូវគំរោង<br>• ភាគីពាក់ព័ន្ធក្នុងមូលដ្ឋានមិនគាំទ្រគំរោង ឬប្រឆាំងជាមួយនឹងគំរោង<br>- |
| 2.4 ការប្រើប្រាស់ទ្រព្យសម្បត្តិសហគមន៍ | ✚ បានកែលំអរការប្រើប្រាស់ទ្រព្យសម្បត្តិសហគមន៍<br>🡅<br>0 គ្មានការផ្លាស់ប្តូរការប្រើប្រាស់ទ្រព្យសម្បត្តិសហគមន៍<br>🡇<br>- កាត់បន្ថយការប្រើប្រាស់ទ្រព្យសម្បត្តិសហគមន៍ |
| 2.5 ការទទួលបានអត្ថប្រយោជន៍សហគមន៍ពីគំរោងដោយស្មើភាពចំពោះសហគមន៍ | ✚ គាំទ្រដល់ក្រុមដែលទន់ខ្សោយឱ្យទទួលបានអត្ថប្រយោន៍សហគមន៍ពីគំរោង<br>🡅<br>0 ការទទួលបានអត្ថប្រយោជន៍សហគមន៍ ពីគំរោងដោយស្មើភាព<br>🡇<br>- ការទទួលបានអត្ថប្រយោជន៍សហគមន៍ ពីគំរោងដោយមិនស្មើភាព |
| 2.6 ការបង្កើតការងារនៅក្នុងប្រទេស | ✚ បង្កើនចំនួនការងារនៅក្នុងលំដាប់ថ្នាក់ជាតិ តំបន់ និងក្នុងស្រុក<br>🡅<br>0 គ្មានការប្រែប្រួលចំនួនការងារ បើប្រៀបធៀបជាមួយលក្ខខណ្ឌគោល គ្មានការបាត់បង់ ឬបង្កើតឡើង<br>🡇<br>- រាល់ការងារដែលបានកំណត់នៅលក្ខខណ្ឌគោលត្រូវបានកាត់បន្ថយ ឬបាត់បង់ |
| 2.7 ផលប៉ះពាល់លើសុខភាពសាធារណៈ | ✚ លើកស្ទួយសុខភាពសាធារណៈ<br>🡅<br>0 គ្មានផលប៉ះពាល់ចំពោះសុខភាពសាធារណៈ<br>🡇<br>- ផលប៉ះពាល់អវិជ្ជមានចំពោះសុខភាពសាធារណៈ |
| 2.8 ភាពស្មើភាពផ្នែកយេនឌ័រ | ✚ លើកកំពល់ភាពស្មើភាពផ្នែកយេនឌ័រ និងសិទ្ធិស្ត្រី<br>🡅<br>0 គ្មានការផ្លាស់ប្តូរភាពស្មើភាពផ្នែកយេនឌ័រ និងសិទ្ធិស្ត្រី<br>🡇<br>- កាត់បន្ថយភាពស្មើភាពផ្នែកយេនឌ័រ និង សិទ្ធិស្ត្រី |
| **ប្រភេទ ទី 3 : ការផ្ទេរបច្ចេកវិទ្យា** | |

| លក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន | ការវាយតំលៃ |
|---|---|
| 3.1 ការផ្ទេរបច្ចេកវិទ្យាសមស្រប និងប្រសើរបំផុតដែលមានប្រើប្រាស់ | + <br>• បច្ចេកវិទ្យាប្រសើរបំផុតដែលមានប្រើប្រាស់នៅក្នុងបណ្ដាប្រទេស ឧស្សាហកម្មជឿនលឿន <br>• បច្ចេកវិទ្យាប្រសើរបំផុតដែលមានប្រើប្រាស់ ហើយដែលបានទទួលការសាកល្បងត្រឹមត្រូវ <br>• បច្ចេកវិទ្យាប្រសើរបំផុតដែលមានប្រើប្រាស់ ហើយដែលអាចថែទាំបានដោយងាយស្រួលនៅក្នុងស្រុក <br>• បច្ចេកវិទ្យាប្រសើរបំផុតដែលមានប្រើប្រាស់ ហើយដែលសមស្របសំរាប់លក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមក្នុងស្រុក <br>↑ <br>0 មានការប្រើប្រាស់បច្ចេកវិទ្យាស្តង់ដា <br>↓ <br>• បច្ចេកវិទ្យាមិនសមស្រប មិនសំរបទៅនឹងតំរូវការ និងសមត្ថភាពក្នុងស្រុក <br>• បរិក្ខា និងជំនាញសំរាប់ថែទាំមិនមាននៅក្នុងប្រទេសកម្ពុជា <br>• បច្ចេកវិទ្យាមិនទាន់បានសាកល្បង ហើយប្រើប្រាស់ប្រទេសកម្ពុជាជាកន្លែងសាកល្បង <br>• បច្ចេកវិទ្យាដែលមិនទទួលការអនុញ្ញាតនៅក្នុងបណ្ដាប្រទេសដើមរបស់វិនិយោគិន <br>- |
| 3.2 ការកសាងសមត្ថភាព | + <br>• ការផ្ទេរជំនាញសំរាប់ប្រើប្រាស់ និងថែទាំបច្ចេកវិទ្យា ឬបរិក្ខា <br>• ការប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុក ដើម្បីដំឡើង និងថែទាំបរិក្ខា <br>• ការបណ្ដុះបណ្ដាលអ្នកបច្ចេកទេសក្នុងស្រុក លើមុខជំនាញដែលពុំមានក្នុងប្រទេសកម្ពុជា <br>↑ <br>0 ការបណ្ដុះបណ្ដាលអ្នកបច្ចេកទេសក្នុងស្រុកលើមុខជំនាញដែលមានស្រាប់ក្នុងប្រទេសកម្ពុជា <br>↓ <br>• គ្មានការផ្ទេរជំនាញអំពីការប្រើប្រាស់ និងថែទាំបច្ចេកវិទ្យា ឬបរិក្ខា <br>• គ្មានការប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុក ដើម្បីដំឡើង និងថែទាំបរិក្ខា |

| លក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន | ការវាយតំលៃ |
|---|---|
| | • ការពឹងផ្អែកលើអ្នកជំនាញការអន្តរជាតិ ដើម្បីដំឡើង ឬថែទាំបរិក្ខា<br>- |
| **ប្រភេទទី 4. ផលប្រយោជន៍សេដ្ឋកិច្ច** | |
| 4.1 ការប្រើប្រាស់មុខជំនួញ និងឧស្សាហកម្មក្នុងស្រុក | ✚<br>• គំរោងធ្វើការដោយផ្ទាល់ជាមួយដៃគូក្នុងស្រុក<br>• ប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុកដើម្បីផលិតឧបករណ៍<br>🡅<br>0 ការប្រើប្រាស់តិចតួចឧស្សាហកម្មក្នុងស្រុក<br>🡇<br>• ក្រុមហ៊ុនក្នុងស្រុកមិនបានចូលរួមនៅក្នុងដំណាក់កាលរៀបចំប្លង់ សាងសង់ អនុវត្ត ឬថែទាំ<br>• ពុំមានជួលក្រុមហ៊ុនក្នុងស្រុកដើម្បីផលិតបរិក្ខា<br>- |
| 4.2 ចំណែកថវិកាគំរោងដែលចំណាយនៅក្នុងប្រទេស | ✚ ជំរុញឱ្យមានការចំណាយថវិកាគំរោងនៅក្នុងប្រទេសឱ្យបានច្រើន<br>🡅<br>0 ជំរុញឱ្យមានការចំណាយថវិកាគំរោងនៅក្នុងប្រទេសឱ្យបាន សមហេតុសមផលសំរាប់សេដ្ឋកិច្ចជាតិ<br>🡇<br>- មានការចំណាយថវិកាតិចតួចនៅក្នុងប្រទេសសំរាប់សេដ្ឋកិច្ចជាតិ |
| 4.3 កាត់បន្ថយភាពពឹងផ្អែកលើឥន្ទនៈ ផូស៊ីល (សំរាប់តែគំរោងថាមពលប៉ុណ្ណោះ) | ✚ កាត់បន្ថយភាពពឹងផ្អែកលើឥន្ទនៈផូស៊ីល<br>🡅<br>0 គ្មានផលប៉ះពាល់ចំពោះភាពពឹងផ្អែកលើឥន្ទនៈផូស៊ីល<br>🡇<br>- ពុំមានការកាត់បន្ថយភាពពឹងផ្អែកលើឥន្ទនៈផូស៊ីល |
| 4.4 កាត់បន្ថយភាពពឹងផ្អែកលើថាមពលនាំចូល (សំរាប់តែគំរោងថាមពលប៉ុណ្ណោះ) | ✚ កាត់បន្ថយភាពពឹងផ្អែកលើថាមពលនាំចូល<br>🡅<br>0 គ្មានផលប៉ះពាល់ចំពោះភាពពឹងផ្អែកលើថាមពលនាំចូល<br>🡇<br>- គ្មានការកាត់បន្ថយភាពពឹងផ្អែកលើថាមពលនាំចូល |

# បញ្ជីគំរោងយន្តការអភិវឌ្ឍន៍ស្អាតនៅកម្ពុជា

| ឈ្មោះគំរោង | ព័ត៌មានសង្ខេបអំពីគំរោង | ស្ថានភាពគំរោង |
|---|---|---|
| (១) គំរោងដុតអង្កាមផលិតថាមពលនិងកំដៅ របស់ក្រុមហ៊ុនអង្គរកសិកម្មរុងរឿង | • ស្ថិតនៅស្រុកអង្គស្នួល ខេត្តកណ្តាល (ចំងាយប្រហែល 23 គម ពីទីក្រុងភ្នំពេញ)<br>• គំរោងបំពាក់ម៉ាស៊ីនដែលមានកំលាំង 1,5 មេហ្គាវ៉ាត់<br>• បរិមាណឧស្ម័នដែលបានកាត់បន្ថយប្រហែល 39.981 តោនសមមូលឧស្ម័នកាបូនិច ក្នុងមួយឆ្នាំ ។ | ឯកសារប្លង់គំរោង (PDD) និងទទួលបានលិខិតអនុញ្ញាតពីស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (DNA) |
| (២) គំរោងចាប់យកឧស្ម័នមេតានពីទីលានចាក់សំរាមស្ទឹងមានជ័យ | • ទីលានចាក់សំរាមស្ទឹងមានជ័យរបស់សាលាក្រុងភ្នំពេញ<br>• មានសំណល់រឹងក្នុងមួយថ្ងៃប្រហែល 7.000 តោន<br>• បរិមាណឧស្ម័នដែលបានកាត់បន្ថយប្រហែល 858.000 តោនសមមូលឧស្ម័នកាបូនិក ក្នុងរយៈពេល 10 ឆ្នាំ ។ | ឯកសារគោលគំនិតគំរោង (PIN) ទទួលបានលិខិតបញ្ជាក់ពីស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (DNA) |
| (៣) គំរោងប្រសិទ្ធភាពចង្ក្រានដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងភាពក្រីក្រនៅកម្ពុជា | • ស្ថិតនៅតាមបណ្តាខេត្តនៅតាមតំបន់ឆ្នេរនៃប្រទេសកម្ពុជា<br>• ចង្ក្រានឡូវថ្មី ចំនួន 14.400 នឹងត្រូវចែកចាយ<br>• បរិមាណឧស្ម័នដែលបានកាត់បន្ថយប្រហែល 858.000 តោន សមមូលឧស្ម័នកាបូនិច ក្នុងមួយឆ្នាំ ។ | ឯកសារគោលគំនិតគំរោង (PIN) |
| (៤) កម្មវិធីជាតិជីវៈឡឧស្ម័ន | • នៅខេត្ត កំពង់ចាម ព្រៃវែង ស្វាយរៀង កំពត តាកែវ និងកំពង់ស្ពឺ<br>• ឡឧស្ម័ននៅតាមផ្ទះចំនួនជាង 17.000 នឹងត្រូវតម្លើងក្នុងចន្លោះឆ្នាំ 2006-2009<br>• បរិមាណឧស្ម័នដែលបានកាត់បន្ថយប្រហែល 41.378 តោនសមមូលឧស្ម័នកាបូនិច ក្នុងមួយឆ្នាំ ។ | ឯកសារគោលគំនិតគំរោង (PIN) ទទួលបានលិខិតបញ្ជាក់ពី ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (DNA) |
| (៥) គំរោងផលិតអគ្គិសនីពីជីវម៉ាសនៅកសិដ្ឋានចិញ្ចឹមជ្រូកសំរោងធំ | • ស្ថិតនៅកសិដ្ឋានចិញ្ចឹមជ្រូកសំរោងធំ តាមបណ្តោយផ្លូវជាតិលេខ 1 ភូមិព្រៃត្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល<br>• បរិមាណឧស្ម័នដែលបានកាត់បន្ថយប្រហែល 7.000-10.000 តោនសមមូលឧស្ម័នកាបូនិច ក្នុងមួយឆ្នាំ ។ | ឯកសារគោលគំនិតគំរោង (PIN) |

## Global climate change and international responses

